**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា**

# ការបម្រើផ្នែកសុខភាពនៅសាលា

## រៀចឆ្អឹងខ្នង - លិខិតផ្ញើជូនមាតាបិតា

ជូនចំពោះមាតាបិតា/អាណាព្យាបាលៈ

ច្បាប់របស់សាលា តម្រូវឲ្យពិនិត្យមើលជម្ងឺរៀចឆ្អឹងខ្នងដល់សិស្សទាំងអស់ដែលរៀនថ្នាក់ទី៦ និងទី៧។

គោលបំណងនៃការពិនិត្យនេះគឺ ដើម្បីរកកន្លែងកោងនៅតាមឆ្អឹងខ្នងរបស់ក្មេង។ បើសិនជាគេឆាប់រកឃើញបញ្ហា ហើយព្យាបាលឲ្យបានត្រឹមត្រូវ វាអាចការពារមិនឲ្យឆ្អឹងខ្នងមានបញ្ហាទៅថ្ងៃក្រោយ។

គិលានុបដ្ឋាកសាលានឹងសង្កេតមើលខ្នងរបស់កូនលោកអ្នកនៅពេលគេឈរ នឹងអោនទៅមុខ។ ដើម្បីអាចឃើញឆ្អឹងច្បាស់ យើងខ្ញុំស្នើសុំឲ្យសិស្សបញ្ចេញសាច់ខ្នង នៅពេលពិនិត្យ។ យើងខ្ញុំសុំឲ្យក្មេងប្រុសពាក់អាវដែលស្រួលដោះចេញ។ ចំពោះក្មេងស្រីវិញ ពាក់អាវហែលទឹក ឬអាវកាក់នៅពីក្រោម។ ថ្ងៃដែលត្រូវពិនិត្យគឺៈ

______________________________________________________________________________

គេនឹងទាក់ទងទៅលោកអ្នកតាមក្រោយ បើមានមូលហេតុដែលកូនលោកអ្នកត្រូវទៅឲ្យវេជ្ជបណ្ឌិតពិនិត្យ។

បើកូនលោកអ្នកកំពុងទទួលការព្យាបាលបញ្ហាឆ្អឹងខ្នង ឬបើសិនជាលោកអ្នកជំទាស់នឹងការពិនិត្យនេះ សូមជម្រាបគិលានុបដ្ឋាកសាលាតាមការសរសេរជាលាយល័ក្ខអក្សរ។ គេនឹងស្នើសុំរបាយការណ៍ពីអ្នកព្យាបាលរបស់លោកអ្នក៕

__________________________________________

គិលានុបដ្ឋាកសាលា/SNP

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer